NATIONAL BOWEL CANCER SCREENING PROGRAM

Australian Government

លេខ ID <Consumer ID>

<Participant Given Name> < Participant Family Name >
<Preferred Mailing Address>
<Preferred Mailing Address >
<Locality> <State> <Postcode>

ជូនចំពោះ <Participant Given Name> < Participant Family Name >

## ការធ្វើតេស្តដោយឥតគិតថ្លៃ ដើម្បីពិនិត្យរកមើលសញ្ញាដំបូងនៃជំងឺមហារីកពោះវៀន

**ពលរដ្ឋអូស្ត្រាលីប្រហែលជា 80 នាក់ស្លាប់រៀងរាល់សប្តាហ៍ ដោយសារជំងឺមហារីកពោះវៀន។**

| | |
|---|---|
| **ការអញ្ជើញ** | លោកអ្នកបានទទួលការអញ្ជើញដើម្បីធ្វើតេស្តពិនិត្យរកមើលសញ្ញាដំបូងនៃជំងឺមហារីកពោះវៀន។ **នេះគឺជាការធ្វើតេស្តឥតគិតថ្លៃ និងងាយស្រួលដែលលោកអ្នកអាចធ្វើបាននៅផ្ទះរបស់លោកអ្នក**។ វាជាការសំខាន់ដែលលោកអ្នកធ្វើតេស្តនេះ ទោះបីជាលោកអ្នកមិនមានរោគសញ្ញាណាមួយ ក៏ដោយ។ ប្រសិនបើរកឃើញបានឆាប់ គេអាចព្យាបាលជំងឺមហារីកពោះវៀនបានដោយជោគ ជ័យ៩០ភាគរយ។ |
| **ហេតុអ្វីបានជា លោកអ្នក ត្រូវបាន អញ្ជើញ ឲ្យចូលរួម?** | អ្នកដែលមានសិទ្ធិចូលរួមអាយុចាប់ពី 50 ឆ្នាំ ទៅ 74 ឆ្នាំ ត្រូវបានអញ្ជើញចូលរួមក្នុងការពិនិត្យរកមើលជំងឺមហារីកពោះវៀន។ ជំងឺមហារីកពោះវៀន គឺជាប្រភេទនៃជំងឺមហារីកទូទៅបំផុតមួយនៅ ក្នុងប្រទេសអូស្ត្រាលី ជាពិសេសចំពោះមនុស្សមានអាយុចាប់ពី 50 ឆ្នាំ។ ជំងឺនេះអាចកើតឡើង ដោយគ្មានរោគសញ្ញា ហើយការធ្វើតេស្តនេះអាចរកឃើញការចេញនូវសញ្ញាព្រមានដំបូង មុនពេល មហារីកពោះវៀនចាប់កើតមានឡើង។ វេជ្ជបណ្ឌិតណែនាំឲ្យធ្វើការពិនិត្យមើលជាទៀងទាត់ដើម្បី រកមើលជំងឺមហារីកពោះវៀន ហើយមានមនុស្សជាច្រើននៅប្រទេសអូស្ត្រាលីធ្វើតេស្តដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការកើតមានជំងឺនេះ។ |
| **តើមានរឿងអ្វី កើតឡើង បន្ទាប់មក?** | នៅក្នុងរយៈពេលពីរបីសប្តាហ៍ខាងមុខនេះ លោកអ្នកនឹងទទួលបានកញ្ចប់មួយដែលមានផ្ទុកនូវ ឧបករណ៍ធ្វើតេស្ត និងការណែនាំមួយចំនួនសម្រាប់លោកអ្នក។ ប្រសិនបើលោកអ្នកមិនមាន បំណងចង់ចូលរួមទេ សូមទូរស័ព្ទទៅខ្សែទូរស័ព្ទផ្តល់ព័ត៌មានរបស់កម្មវិធីនេះលេខ 1800 118 868។ |
| **តើលោកអ្នក មានសំណួរ ណាមួយឬទេ?** | សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ទូរស័ព្ទខ្សែទូរស័ព្ទផ្តល់ព័ត៌មានរបស់កម្មវិធីនេះ ឬបើកមើលវ៉ិបសាយរបស់យើងខ្ញុំ www.cancerscreening.gov.au។ |

**ការធ្វើតេស្តនេះ អាចជួយសង្គ្រោះជីវិតរបស់លោកអ្នក។**

សាស្ត្រាចារ្យ Brendan Murphy
ប្រធានវេជ្ជសាស្រ្ត

<DATE>

NBCSR XXXX